# ល្អាងគំនូរ ភ្នំក្រវាញ

គំនូរនៅតាមរូងភ្នំ ជញ្ជាំងថ្ម ត្រូវបានរកឃើញជាច្រើនកន្លែងនៅលើពិភពលោក ដូចជានៅអាហ្វ្រិច អ៊ឺរ៉ុប អាមេរិក អូស្ត្រាលី និងអាស៊ីជាដើម ។ គំនូរត្រូវបានមនុស្សប្រើប្រាស់ជាយូរណាស់មកហើយ ដូចជានៅរូងភ្នំ Lascaux ប្រទេសបារាំង ដែលមានអាយុកាលចន្លោះ ៣៥០០០ឆ្នាំ-១០០០០ឆ្នាំ[១] ដែលជាសិល្បៈគំនូរក្នុងរូងភ្នំដ៏ចំណាស់ ។ ក្នុងនោះក៏មានការសិក្សាពីតំបន់អាស៊ីផងដែរ ដូចជានៅប្រទេសថៃដែលមានបង្ហាញអំពីគំនូរពណ៌ក្រហមក្នុងរូងភ្នំ បង្ហាញអំពីមនុស្ស បាញ់ព្រួញ សត្វគោ ដែលគេកំណត់អាយុចន្លោះ ៤០០០ មក២៥០០ ឆ្នាំមុនបច្ចុប្បន្ន។[២] នៅប្រទេសកម្ពុជាក៏បានរកឃើញមាននៅ២តំបន់ គឺនៅតំបន់ភ្នំក្រវាញ និងតំបន់ភ្នំគូលែន។ ភ្នំគូលែនត្រូវបានរកឃើញគំនូរប្រភេទនេះ ចំនួន ៨ទីតាំងរួចមកហើយ[៣] និងអាចមានទីតាំងផ្សេងទៀតដែលយើងពុំទាន់រកឃើញ ដ្បិតទីតាំងនេះមានស្លាកស្នាមបុរាណខ្លះនៅអាថ៌កំបាំងនៅឡើយ។

ភ្នំក្រវាញជាតំបន់ជួរភ្នំមួយនៃប្រទេសកម្ពុជា ដែលលាតសន្ធឹងក្នុងខេត្តមួយចំនួន ដូចជាខេត្តបាត់ដំបង ពោធិ៍សាត់ កោះកុង កំពង់ឆ្នាំង កំពង់ស្ពឺ ព្រះសីហនុ កំពត។ តំបន់នេះជាតំបន់ភ្នំ ព្រៃឈើ និងជីវចម្រុះដែលនៅមានអាថ៌កំបាំងជាច្រើន។ តាមរយៈផែនទីភូគព្ភសាស្ត្រនៃព្រះរាជាណាចក្រកម្ពុជាតំបន់នេះ ជាតំបន់ដែលស្ថិតនៅក្នុង ស័កទី២ ក្នុងសម័យ Jurassic និងCretaceous។[៤] តំបន់នេះមានប្រជាជនរស់នៅតិចតួច ពិសេសគឺជនជាតិភាគតិច ដូចជាជនជាតិសួយ ជនជាតិព័រ ជងជាដើម។ បច្ចុប្បន្ននេះប្រជាជនបានចំណាកស្រុកផ្លាស់ប្តូរទីកន្លែងរស់នៅ កន្លែងខ្លះបានបាត់បង់ព័ត៌មានស្ទើរទាំងស្រុងដូចជា ប្រពៃណីវប្បធម៌ជាដើម។ ល្អាងគំនូរ ស្ថិតនៅក្នុងតំបន់ឧទ្យានជាតិក្រវាញកណ្តាល ខាងត្បូងភូមិកាណម ឃុំរការ ស្រុកក្រវាញ ប្រមាណ៤០គ.មពីទីរួមស្រុក មានចំនុច និយាមការ X: 370531 Y: 1338553 ។

---

[១] https://hoopermuseum.earthsci.carleton.ca/2001_human_ka/genushomo18.html

[២] Noel Hidalgo Tan, 2014 Rock Art Research in Southeast Asia: A Synthesis, p.76

[៣] ឆ្នាំ២០១៥, បញ្ជីបុរាណស្ថាន ក្នុងឧទ្យានជាតិព្រះជ័យវរ្ម័ន-នរោត្តម «ភ្នំគូលែន»

[៤] General Department of Mineral Resource,2010, Geological Map of Cambodia

អត្ថបទដោយ៖ លឹម វណ្ណចន្ទ័

ការធ្វើដំណើរទៅកាន់តំបន់នោះមានការលំបាកខ្លះ (រូបលេខ១-២) ក្រុមការងារបានចុះទៅពិនិត្យ ១៥-១៦ ខែមិថុនា ឆ្នាំ២០២១។ ល្អាងគំនូរ(នៅភ្នំគូលែនហៅថាពើង) ដែលមានដុំថ្មធំមួយគ្របពីលើ ហើយផ្នែកខាងក្រោមអាចជ្រកភ្លៀងបាន ឬរស់នៅបាន។ ថ្មនេះមានទំហំប្រមាណ៤គុណ និង៥ម៉ែត្រ(រូបលេខ៣)។ ដោយរូបគំនូរទាំងឡាយស្ថិតនៅផ្នែកពិដាននៃថ្មខាងលើ និងមានបំណែកថ្មមួយដុំទៀតនៅផ្នែកខាងក្រោម ដែលមានស្លាកស្នាមពណ៌ដីលែងនៅលើនោះផងដែរ។

ស្ថានភាពគំនូរ គូរដោយពណ៌ក្រហម មានសភាពរលប់ដោយសារអាយុកាល ហើយកន្លែងខ្លះអាចមើលយល់ ខ្លះពិបាកយល់។ ការគូរនៅមានលក្ខណៈសាមញ្ញ បង្ហាញអំពីមនុស្សជិះដំរី សត្វព្រៃផ្សេងៗ និងសម្ភារៈមួយចំនួន ដូចខាងក្រោម៖

១. មនុស្សជិះដំរី នៅក្នុងរូបលខ៤-៥-៦-៧ និង៨

រូបលេខ៤ ផ្នែកខាងស្ដាំបង្ហាញអំពីមនុស្សម្នាក់ជិះដំរី។ រូបលេខ៥ ជារូបខាងឆ្វេងនៃរូបលេខ៤ ជារូបមនុស្ស៣នាក់ជិះដំរី ដែលស្ថិតនៅលើជញ្ជាំងបញ្ឈរ។ រូបលេខ៦ជារូបដែលគូរលើពិដានថ្មជារូបតូចៗ មានមនុស្ស៤នាក់ដែលបង្ហាញពីសកម្មភាពតោងបន្តគ្នា ចំនុចជាការចាប់អារម្មណ៍មួយដែលអាចគិតថាវាគួរមានទំនាក់ទំនងនឹងការទាក់ដំរី។[៥] រូបលេខ៧-៨ បង្ហាញពីមនុស្សម្នាក់ជិះដំរី ដែលស្ថិតនៅក្នុងក្រុមនៃពពួកសត្វព្រៃមួយចំនួន ព្រមទាំងអាចមានរូបដំរីផ្សេងទៀតផងដែរ។ ក្នុងគំនូរប្រភេទនេះពេលខ្លះមានការលំបាកនៅក្នុងការកំណត់ថាតើពួកគាត់កំពង់ធ្វើអ្វី? នេះអាចជាសកម្មភាពទៅបរបាញ់សត្វ ឬយ៉ាងណា?

២. សត្វព្រៃ ដែលមានក្នុងគំនូរមានការលំបាកក្នុងការកំណត់អត្តសញ្ញាណ តែយើងយល់ទៅតាមទម្រង់ ភាគច្រើនជាពពួកឈ្លូស ប្រើស ក្ដាន់ជាដើម ដែលត្រូវបានគូរមានចំនួនច្រើន និងមានទំហំតូចៗប្រមាណ១០ស.ម។ តាមរយៈរូបលេខ៩ នេះគឺរូបដែលបង្ហាញពីពពួកឈ្លូស ប្រើស ក្ដាន់ ដែលគូរមានបញ្ច្រាសគ្នា នៅផ្នែកកណ្ដាលហាក់មានសត្វដំរីមួយក្បាលផងដែរ។ រូបលេខ១០-១១ ហាក់ជាពពួកសត្វគោ ឬទន្សោង ឬខ្ទីង។ រូបលេខ១២ យើងអាចយល់ថាជាជាប្រភេទពពួកប្រើស ឬក្ដាន់ ដោយហេតុថាវាមានស្នែង

[៥] ធ្នូ ២០១០-ធ្នូ ២០១១, កម្រងអត្ថបទ ក្នុង បណ្ដាញពត៌មានវប្បធម៌ខ្មែរ, ទំព័រ ១០០

បែកចេញពីគ្នា។ ចំពោះរូបលេខ១៣ អាចជាពពួកឈ្លូស ឬប្រភេទសត្វណាមួយ តែក្នុងនោះផងដែរក៏ហាក់ដូចជាមានរូបមនុស្សកំពង់ចាប់សត្វនោះ។

៣. សម្ភារៈប្រើប្រាស់

នៅក្នុងរូបគំនូរទាំងនេះ តាមរយៈសកម្មភាព ដូចជារូបលេខ១៤ ត្រង់ចំនុចរង្វង់រូបខាងស្ដាំជាហ្មរដំរី ដែលដាំកាន់កង្វេរ។ រង្វង់ខាងឆ្វេង រូបមនុស្សទី២ទាញអ្នកទី៣ដែលក្នុងដៃមានកាន់ជារបស់អ្វី១? អាចចាផ្ទុ កាំបិតផ្គាក់? សម្រាប់រូបគំនូរលេខ១៥ និងលេខ១៦ អាចជារូបនង្គ័ល តាមរយៈរូបនេះអាចយល់បានថា ការប្រើកង្វេរ និងនង្គ័ល មានន័យថាមនុស្សចេះប្រើប្រាស់លោហៈ និងចេះធ្វើកសិកម្មអចិន្ត្រៃ។

ជនជាតិដែលរស់នៅតំបន់នោះ ភូមិកាណម ជនជាតិព័រ គាត់រស់នៅតំបន់ក្រវាញ តែត្រូវបានផ្លាស់ផ្ទូរក្នុងសម័យខ្មែរក្រហម រហូតដល់ឆ្នាំ១៩៩៨ មាន៤គ្រួសារត្រលប់មករស់នៅភូមិនេះវិញ។[៦] ពួកគាត់នៅគោរពចំពោះល្អាងគំនូរ ដោយឃើញមានកន្ទែងដាក់ក្រឡដាក់ឆ្អឹង និងម្ល្បូសបុរាណ ក្នុងតំបន់នេះដែរ។ ក្រុមស្រាវជ្រាវមួយក្រុមដែលធ្លាប់សិក្សានៅតំបន់នោះ ក៏បានបង្ហាញពីវត្តមានរបស់វត្ថុប្រើប្រាស់ ពីយុគថ្មរំលីង យុគលោហៈពាងសម័យអង្គរ សម័យកណ្ដាល និងបន្តមកក្រោយទៀត។[៧] ថ្មីៗតាមរយៈលោក ឡាម៉ូ ដែលជាអ្នកថតរូបគាត់ក៏បានបង្ហាញពីទីតាំងមួយ ដែលមានក្រឡដាក់ឆ្អឹង និងមានស្នាកស្នាមគំនូរនៅពិដានរូងភ្នំនៅ រូងជំនាង គ្រាន់តែមើលមិនយល់ និងនៅសល់ស្នាកស្នាមតិចតួចពេក ក្នុងភូមិសាស្ត្រខេត្តកោះកុង ក្នុងតំបន់ភ្នំក្រវាញផងដែរ។ ក្នុងរាជព្រះអង្គច័ន្ទរាជាក្នុងអំឡុងស.វទី១៦គ.ស ជនជាតិដែលរស់នៅតំបន់ក្រវាញនោះគឺមានទំនាក់ទំនងច្រើនដូចជាការទាក់ដំរី។[៨] ចំពោះអាយុកាលគឺមិនទាន់ច្បាស់លាស់នោះទេ តែតាមរយៈរូបយើងអាចយល់ថា ពួកគាត់ចេះប្រើប្រាស់លោហៈធ្វើកសិកម្មអចិន្ត្រៃ ចិញ្ចឹមសត្វរួចទៅហើយ។ អាចអាយុកាលស្ថិតនៅចន្លោះ រវាងយុគលោហៈ បន្តមកសម័យកណ្ដាល។

---

[៦] 2003 – 2004, BASELINE SOCIO-ECONOMIC STUDIES OF PHNOM AURAL WILDLIFE SANCTUARY, CAMBODIA, P.91

[៧] April 2016, The Kanam Rock Painting Site, Cambodia: Current Assessments, P. 67

[៨] រាជពង្សាវតាខ្មែរ ភាគ១-២

អត្ថបទដោយ៖ លឹម វណ្ណច័ន្ទ




រូបលេខ២១

រូបលេខ២២




រូបលេខ២៣

រូបលេខ២៤




រូបលេខ២៥

រូបលេខ២៦




អត្ថបទដោយ៖ លឹម វណ្ណច័ន្ទ

រូបលេខ៧ រូបលេខ៨



រូបលេខ៩





រូបលេខ១០ រូបលេខ១១





រូបលេខ១២ រូបលេខ១៣

អត្ថបទដោយ៖ លឹម វណ្ណច័ន្ទ



រូបលេខ១៤



រូបលេខ១៥



រូបលេខ១៦

អត្ថបទដោយ៖ លឹម វណ្ណចន្ទ